# សេចក្តីថ្លែងការណ៍រួម

## ស្តីពី

# ការការពារ និងលើកកំពស់សិទ្ធិពលករទេសន្តរប្រវេសន៍កម្ពុជា

*ភ្នំពេញ, ថ្ងៃទី១៨ ខែ ធ្នូ ឆ្នាំ ២០១០*

យើងខ្ញុំជាតំណាងឱ្យអង្គការមិនមែនរដ្ឋាភិបាល ដែលមានសមាសភាពជាង ២០ អង្គការ-សមាគម ធ្វើការលើវិស័យទេសន្តរប្រវេសន៍ សិទ្ធិមនុស្ស ស្ត្រី និងកុមារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា សូមសំដែងនូវការអបអរសាទរចំពោះរាជរដ្ឋាភិបាលកម្ពុជាក្នុងឱកាសដែលពិភពលោកប្រារព្ធខួបលើកទី២០នៃទិវាជនចំណាកស្រុកអន្តរជាតិ ១៨ ធ្នូ និងខួបលើកទី៥ សម្រាប់ព្រះរាជាណាចក្រកម្ពុជា ដែលផ្តួចផ្តើមប្រារព្ធធ្វើឡើងដោយអង្គការខារ៉ាមកម្ពុជា ក្នុងកិច្ចសហការជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ចាប់តាំងពី ឆ្នាំ២០០៦ ដែលបានយកចិត្តទុកដាក់ក្នុងការការពារ និង លើកកំពស់សិទ្ធិពលករទេសន្តរប្រវេសន៍ ការបង្កើតគោលនយោបាយស្តីពីទេសន្តរប្រវេសន៍ ក្រុមការងារអន្តរក្រសួងស្តីពីទេសន្តរប្រវេសន៍ និង ការដំណើរការរៀបចំធ្វើវិសោធនកម្មអនុក្រឹតលេខ៥៧ស្តីពីការបញ្ជូនពលករកម្ពុជាទៅធ្វើការងារនៅក្រៅប្រទេស ការចេញនូវអនុក្រឹត្យស្តីពីការផ្តល់លិខិតឆ្លងដែនដល់ពលករក្នុងតម្លៃសមស្រប ការចេញនូវឯកសារណែនាំតម្រង់ទិសមុនចេញដំណើរសម្រាប់ពលករទេសន្តរប្រវេសន៍ ជាពិសេស ការបង្ក្រាបទៅលើក្រុមហ៊ុនជ្រើសរើសពលករ ដែលបានបង្ខាំងមនុស្សដោយខុសច្បាប់នាពេលថ្មីៗកន្លងទៅនេះ។

ទោះបីយ៉ាងណាក៏ដោយ អង្គការសង្គមស៊ីវិលដែលធ្វើការងារទៅលើវិស័យពលករទេសន្តរប្រវេសន៍ សិទ្ធិមនុស្ស ស្ត្រី និងកុមារ នៅតែមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះការបន្តកើតមានការរំលោភបំពាននានា ទៅលើពលករទេសន្តរប្រវេសន៍ដូចជា ការចាប់ខ្លួន ការឃុំខ្លួន ការនិរទេស និង ការធ្វើមាតុភូមិនិវត្តន៍ កង្វះការទទួលខុសត្រូវរបស់និយោជកនៅពេលដែលពលករទទួលរងគ្រោះថ្នាក់ការងារ ការក្លែងលិខិតសាធារណៈ ការបង្ខាំងមនុស្សដោយខុសច្បាប់ ការធ្វើអោយជាប់បំណុលក្រុមហ៊ុនជ្រើសរើសពលករ ការធ្វើកិច្ចសន្យាការងារដែលមិនមានលក្ខណៈច្បាស់លាស់ ឬ កិច្ចសន្យាដែលមិនមានបទដ្ឋានអាចអនុវត្តបាននៅប្រទេសទទួល កង្វះព័ត៌មានស្តីពីទេសន្តប្រវេសន៍ប្រកបដោយសុវត្ថិភាព ការធ្វើតេស្តឈាមរកមេរោគអេដស៍ដោយបង្ខំ ការរើសអើងចំពោះស្ត្រីមានផ្ទៃពោះ ការកាត់ប្រាក់បៀវត្សដោយមិនមានហេតុផលសមរម្យ លក្ខខ័ណ្ឌការងារធ្ងន់ធ្ងរ (ការធ្វើការងារលើសម៉ោង មិនមានថ្ងៃឈប់សំរាក...) មិនមានការធានា

ារ៉ាប់រងផ្នែកសុខភាពនិងការងារ ការបំបិទសិទ្ធិសេរីភាព កង្វះការទទួលបានជំនួយផ្លូវច្បាប់ និងសេវាសង្គមផ្សេងៗ ការដកយកលិខិតឆ្លងដែន និងឯកសារគតិយុត្តិផ្សេងៗ ឧបសគ្គភាសា អំពើហិង្សា និងទំរង់កេងប្រវ័ញ្ចផ្សេងៗ ។ល។

ហេតុដូច្នេះហើយ ឆ្លៀតក្នុងឱកាសដែលពិភពលោកប្រារព្ធខួបលើកទី២០នៃទិវាជនចំណាកស្រុកអន្តរជាតិ ១៨ធ្នូ បន្ទាប់ពីមហាសន្និបាទអង្គការសហប្រជាជាតិបានអនុម័តអនុសញ្ញាអន្តរជាតិស្តីពីការការពារពលករទេសន្តរប្រវេសន៍ និង សមាជិកក្រុមគ្រួសាររបស់គេ យើងខ្ញុំជាក្រុមអង្គការសង្គមស៊ីវិល សូមលើកជូននូវអនុសាសន៍មួយចំនួនសម្រាប់ រាជ-រដ្ឋាភិបាលកម្ពុជាដូចតទៅ:

១- បង្កើតយន្តការដើម្បីទទួល និងដោះស្រាយពាក្យបណ្តឹងរបស់ពលលករទេសន្តប្រវេសន៍ នៅពេលដែលមានវិវាទការងារជាមួយនិយោជក ។

២- បន្តចរចាជាមួយរដ្ឋាភិបាលនៃប្រទេសទទួលក្នុងការបង្កើតអនុស្សារណៈនៃការយោគយល់គ្នា ឬកិច្ចព្រមព្រៀងទ្វេរភាគី ក្នុងការបញ្ជូនពលករកម្ពុជាទៅធ្វើការងារនៅក្រៅប្រទេស ។

៣- បង្កើតក្រុមការងារដើម្បីស្រាវជ្រាវ និងស៊ើបអង្កេតពាក់ពន្ធ័នឹងការចាប់ខ្លួន ការឃុំខ្លួន ការនិរទេស និងការបាត់ខ្លួនពលករនៅប្រទេសទទួល ។

៤- ពិចារណាក្នុងការបង្កើតឱ្យមាននូវកិច្ចព្រមព្រៀងស្តីពី “*កញ្ចប់ធានារ៉ាប់រងសេវាសុខភាពជាស្តង់ដារ*” មួយ ដែលនឹងត្រូវផ្តល់ដោយប្រទេសទទួល (ដោយសហការជាមួយប្រទេសបញ្ជូន) ដើម្បីជួយធានារ៉ាប់រងសុខភាពរបស់ពលករក្នុងពេលបំពេញការងារនៅប្រទេសទទួល ជាពិសេសសំរាប់ស្ត្រីភេទ នូវសេវាសុខភាពសាធារណៈដូចជា: សេវាបង្ការ ព្យាបាល និងសេវាពិនិត្យសុខភាពបន្តពូជ និងការមានផ្ទៃពោះ ជាដើម ។

៥- ចរចាជាមួយរដ្ឋាភិបាលប្រទេសទទួល ទាក់ទិនទៅនឹងការដកហូតលិខិឆ្លងដែន ឬឯកសារសំគាល់ខ្លួនជាផ្លូវការរបស់ពលករទេសន្តរប្រវេសន៍ស្របច្បាប់ដោយក្រុមហ៊ុនឯកជន ឬអ្នកទទួលនៃប្រទេសផ្តល់ការងារ ។

៦- ពន្លឿនដំណើរការធ្វើវិសោធនកម្ម អនុក្រឹត្យលេខ៥៧ស្តីពីការបញ្ជូនពលករទេសន្តប្រវេសន៍ទៅក្រៅប្រទេសដោយធ្វើកិច្ចពិគ្រោះយោបល់ជាមួយសង្គមស៊ីវិល និងអនុវត្តគោលនយោបាយទេសន្តប្រវេសន៍ការងារអោយមានប្រសិទ្ធិភាព ។

៧- ចរចាជាមួយរដ្ឋាភិបាលប្រទេសទទួល ដើម្បីបង្កើតឱ្យមានកិច្ចសន្យាបទដ្ឋានមួយ អាចអនុវត្តបាននៅប្រទេសទទួល ដោយមានចែងអំពីលក្ខខណ្ឌការងារច្បាស់លាស់ (ដូចជា: ថ្ងៃឈប់សំរាក ការឈប់សំរាកមាតុភាព ការឈប់សំរាកប្រចាំឆ្នាំ ។ល។) ហើយធានានូវសិទ្ធិការងារជាមូលដ្ឋាន ជាពិសេស ការងារបំរើតាមផ្ទះត្រូវបានដាក់បញ្ចូលនៅក្នុងច្បាប់ការងារ ។

៨- លុបបំបាត់ការបង្ខំអោយធ្វើតេស្តឈាមរកមេរោគអេដស៍ និងការមានផ្ទៃពោះ ។

៩- រឹតបន្តឹងយន្តការត្រួតពិនិត្យទៅលើគោលនយោបាយ កិច្ចសន្យាការងារ និងនីតិវិធីនានាក្នុងការជ្រើសរើសរបស់ក្រុមហ៊ុន ឬ ភ្នាក់ងារជ្រើសរើសពលករទេសន្តប្រវេសន៍កម្ពុជាអោយធ្វើការនៅក្រៅប្រទេស ដោយកំណត់ឱ្យបានច្បាស់លាស់នូវកាតព្វកិច្ច និងការទទួលខុសត្រូវរបស់ភ្នាក់ងារជ្រើសរើសទាំងនោះ ដែលចាំបាច់ត្រូវតែទទួលស្គាល់ជាផ្លូវការដោយរាជរដ្ឋាភិបាលកម្ពុជា ជាពិសេស ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មុននឹងអនុញ្ញាតឱ្យដំណើរការសកម្មភាពផ្សេងៗ។

១០- កំណត់គោលការណ៍អំពីការកំណត់ថ្លៃសមរម្យ ក្នុងការរៀបចំឯកសារសំរាប់ការចេញដំណើរទៅធ្វើការនៅប្រទេសទទួល និងកំណត់បទដ្ឋានគ្រប់គ្រងមណ្ឌលបណ្តុះបណ្តាលរបស់ក្រុមហ៊ុនជ្រើសរើសពលករ អោយមានប្រសិទ្ធភាព។

១១- ផ្តល់វគ្គបណ្តុះបណ្តាលមុនពេលចេញដំណើរដល់ពលករអំពីសិទ្ធិការងារជាមូលដ្ឋាន និងព័ត៌មានអំពីការធ្វើទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាពដោយសហការជាមួយសង្គមស៊ីវិល និងស្ថាប័នពាក់ព័ន្ធ។

១២- ផ្តន្ទាទោសឱ្យបានពិតប្រាកដភ្នាក់ងារជ្រើសរើសពលករទេសន្តប្រវេសន៍ណាដែលបង្កបទល្មើសព្រហ្មទណ្ឌ ដូចជា: ការឃុំឃាំងបំបិទសិទ្ធិសេរីភាព ការបង្ករបួសស្នាម ការក្លែងលិខិតសាធារណៈ ការរំលោភបំពានលើរូបរាងកាយ និងផ្លូវភេទ។

១៣- បង្កើតសេនានុព័ន្ធការងារនៅតាមស្ថានទូតកម្ពុជាប្រចាំប្រទេសទទួល និង បណ្តុះបណ្តាលមន្ត្រីសេនានុព័ន្ធការងារ និងមន្ត្រីរដ្ឋាភិបាលនានាអំពីបញ្ហាទេសន្តប្រវេសន៍ ដើម្បីការពារ និងលើកកំពស់សិទ្ធិពលករទេសន្តរប្រវេសន៍។

*សំរាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង*

១. **លោក យ៉ា ណាវុធ** នាយកប្រតិបត្តិអង្គការខារ៉ាមកម្ពុជា (CARAM Cambodia) ០១២ ៩៦១ ៤២៧

២. **លោក សួន សារ៉េត** ប្រធានលេខាធិការដ្ឋាន គណៈកម្មាធិការប្រព្រឹត្តកម្ម (CHRAC) ០៩២ ៣៤៤ ៣៩៧